# សេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ
# សម្រាប់កិច្ចសន្យាការងារសាងសង់ប៉មយាមសហគមន៍នេសាទ
# ក្រោមក្របខ័ណ្ឌមូលនិធិទ្រទ្រង់ជីវភាពសហគមន៍នៃគម្រោងទ្រទ្រង់ជីវភាពប្រជាជនបឹងទន្លេសាប

| ខេត្ត : សៀមរាប | ស្រុក : ពួក | ឃុំ : កែវពណ៌ |
|---|---|---|

ការពិពណ៌នាអំពីលទ្ធផលកិច្ចសន្យា : សាងសង់ប៉មយាម១កន្លែង ដែលមានទីតាំងនៅបឹងមេពូជត្រពាំងច្រាំង

| | |
|---|---|
| តម្លៃប៉ាន់ស្មាន | ៥៧២៤.៦៤ ដុល្លារ *( ប្រាំពាន់ប្រាំពីរយម្ភៃបួនដុល្លា និងហុកសិបបួនសេន )* |
| រយៈពេលអនុវត្ត | ០៣ ខែ |
| អ្នកដែលអាចដេញថ្លៃ | អ្នកទទួលការប្រភេទទី១ ដែលមានឈ្មោះក្នុងបញ្ជីខេត្ត-រាជធានី |
| ទីកន្លែងដែលអាចទទួលឯកសារដេញថ្លៃ | *សាលាឃុំកែវពណ៌ រឺ ការិយាល័យក្រុមទ្រទ្រង់ជីវភាពសហគមន៍ខេត្តសៀមរាប ចាប់ពីថ្ងៃផ្សព្វផ្សាយពត៌មាននេះ នៅរៀងរាល់ថ្ងៃ និង ម៉ោងធ្វើការ ។* |
| ទីកន្លែងនៃការប្រជុំបើកសំណើដេញថ្លៃ | សាលាឃុំកែវពណ៌ ស្រុកពួក ខេត្តសៀមរាប |
| កាលបរិច្ឆេទនៃការប្រជុំបើកសំណើដេញថ្លៃ | ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១០ |
| • ពេលវេលាឈប់ទទួលសំណើដេញថ្លៃ | វេលាម៉ោង : ០៩.០០នាទីព្រឹក |
| • ពេលវេលាបើកសំណើដេញថ្លៃ | វេលាម៉ោង : ០៩.១៥ នាទីព្រឹក |

កំណត់សម្គាល់ :

- អ្នកទទួលការត្រូវទទួលខុសត្រូវទាំងស្រុងក្នុងការថែទាំលទ្ធផលកិច្ចសន្យា និងជួសជុលនូវរាល់ការខូចខាតទាំងអស់ នៅក្នុងអំឡុងពេល៦ខែ បន្ទាប់ពីសាងសង់រួចជាស្ថាពរ ។
- អ្នកទទួលការត្រូវចូលរួមដេញថ្លៃប្រកបដោយការប្រកួតប្រជែង ដោយគ្មានឃុបឃិតស៊ីគ្រលំគ្នា និងមិនពាក់ព័ន្ធនឹងការក្លែងបន្លំ ឬអំពើពុករលួយ។ ប្រសិនបើអ្នកទទួលការណាឃុបឃិតស៊ីគ្រលំគ្នា ឬពាក់ព័ន្ធក្នុងការក្លែងបន្លំ ឬអំពើពុករលួយជាមួយអ្នកទទួលការដទៃ អ្នកទទួលការទាំងនោះនឹងត្រូវលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកទទួលការជារៀងរហូត និងមិនត្រូវបានអនុញ្ញាតឱ្យដាក់សំណើដេញថ្លៃគម្រោងឃុំទាំងអស់នៅទូទាំងប្រទេសកម្ពុជា។

***ពត៌មានទំនាក់ទំនង***

- *លោក លួស ឡាយ ទូរស័ព្ទ ០១២ ៩០១ ៤២៥*
- *លោកស្រី រសៀល វ៉ានធឿន ទូរស័ព្ទ ០១២ ២៥៣ ៤៥៧*

ថ្ងៃទី...២៤......ខែ..មករា...ឆ្នាំ២០១០

**មេឃុំ**

Luoslay

លួស.ឡាយ

# សេចក្តីជូនដំណឹង

## ស្តីពី

**ការដេញថ្លៃសម្រាប់កិច្ចសន្យាការងារគម្រោងសាងសង់ប៉មយាមបឹងមេពូជ ០១ កន្លែង នៅភូមិទពាំងត្រាំង ឃុំកែវពណ៌ ស្រុកពួក ខេត្តសៀមរាប ក្រោមក្របខណ្ឌមូលនិធិទ្រទ្រង់ជីវភាពសហគមន៍ នៃគម្រោងទ្រទ្រង់ជីវភាពប្រជាជនបឹងទន្លេសាប**

ក្រុមប្រឹក្សាឃុំកែវពណិ ស្រុកពួក ខេត្តសៀមរាប មានកិត្តិយស សូមជំរាបជូនដល់ អស់លោក លោកស្រី ប្រធានក្រុមហ៊ុនទទួលការសំណង់ ទាំងអស់ជ្រាបថាៈក្រុមប្រឹក្សាឃុំយើងខ្ញុំសូមប្រកាសជ្រើសរើសអ្នកទទួលការ ដើម្បីធ្វើការដេញថ្លៃ អនុវត្តគម្រោងសាងសង់ប៉មយាមបឹងមេពូជ ចំនួន ០១ កន្លែង ដែលមានតម្លៃប៉ាន់ស្មាន ចំនួន ៥,៧២៤.៦៤ ដុល្លារ (ប្រាំពាន់ប្រាំពីររយម្ភៃបួនដុល្លារអាមេរិក និងហុកសិបបួនសេន )សម្រាប់ការអនុវត្តនៅ ឆ្នាំ២០១០ ដោយប្រើថវិការបស់ឃុំ ដែល បានទទួលបានការឧបត្ថម្ភពីធនាគារអភិ វឌ្ឍន៍អាស៊ី **ADB** តាមរយៈក្រសួងមហាផ្ទៃ នៃគម្រោងទ្រទ្រង់ជីវភាពប្រជាជនបឹងទន្លេសាប **TSSL** ។

***<u>លក្ខខណ្ឌជ្រើសរើស</u>***

- អាចដាក់ពាក្យក្នុងនាមជាបុគ្គល ឬ ក្រុមហ៊ុន
- មិនស្ថិតនៅក្នុងបញ្ជីខ្មៅរបស់ធនាគារអភិវឌ្ឍន៍អាស៊ី **ADB**
- ជាអ្នកទទួលការប្រភេទ១ ដែលមានឈ្មោះក្នុងបញ្ជីអ្នកទទួលការ ទទួលស្គាល់ដោយអភិបាលខេត្ត-រាជធានី ។

***<u>កាលបរិច្ឆេទដេញថ្លៃ</u>*** :

- ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០១០ ដោយឈប់ទទួលសំណើដេញថ្លៃនៅវេលាម៉ោង ០៩ : ០០ នាទីព្រឹក នាថ្ងៃដដែល ។

អាស្រ័យហេតុនេះ សូម អស់លោក លោកស្រី ដែលមានចំណាប់អារម្មណ៍ និង មានលក្ខណៈសម្បត្តិតាមលក្ខខ័ណ្ឌនៃការជ្រើសរើសខាងលើនេះ សូមអញ្ជើញ មកទទួលយកទំរង់សំណើដេញថ្លៃ នៅសាលាឃុំ ឬនៅការិយាល័យ គម្រោង សម្របសម្រួលជីវភាព សហគមន៍ ខេត្តសៀមរាប (**សាលាខេត្ត**) អោយបានមុនថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០១០ នៅទីកន្លែងដដែល ។ រាល់ពត៌មានបន្ថែមសូមទំនាក់ទំនងឃុំតាមទូរសព្ទ័លេខ: **012 901 425** , **012 253 457**

**មេឃុំ**

ស្រុក ... កែវពណ៌

ឡុង ស. ឡាយ